# សេចក្តីជូនដំណឹងស្តីពីការធ្វើបរិវិសកម្ម

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ហៅកាត់ថា **ក្រុមហ៊ុន ឌី ប៊ី ឌី** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជន មេត្តាជ្រាបថា ក្រុមហ៊ុនយើងខ្ញុំបានទទួលការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា (ន.ម.ក) សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈតាមរយៈសេចក្តីសម្រេចលេខ ១២៣/២១ ន.ម.ក/ស.ស.រ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១។ អាស្រ័យហេតុនេះ **ក្រុមហ៊ុន ឌី ប៊ី ឌី** ដោយមានជំនួយពី **ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី** ជាទីប្រឹក្សាហិរញ្ញវត្ថុ និងក្រុមហ៊ុនធានាទិញមូលបត្រ សូមអញ្ជើញ វិនិយោគិនដែលមានបំណងធ្វើបរិវិសកម្ម អញ្ជើញដាក់ពាក្យស្នើសុំចូលរួមធ្វើបរិវិសកម្មនៃសំណើលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈរបស់ក្រុមហ៊ុនយើងខ្ញុំ។

## ១. ការលើកទឹកចិត្តពិសេសសម្រាប់វិនិយោគិនចូលរួមក្នុងការបោះ-ផ្សាយលក់មូលបត្រកម្មសិទ្ធិ លើកដំបូងជាសាធារណៈ - ការធានាទិន្នផលភាគលាភអប្បបរមាក្នុងអត្រាខ្ពស់បំផុតមិនធ្លាប់មានពីមុនមក

- ការធានាទិន្នផលភាគលាភអប្បបរមាក្នុងអត្រា ៥,៥% ក្នុងមួយឆ្នាំសម្រាប់រយៈពេល៣ឆ្នាំ។
- នេះគឺជាអត្រាទិន្នផលភាគលាភអប្បបរមាដែលខ្ពស់បំផុតក្នុងចំណោមក្រុមហ៊ុនដែលបានចុះបញ្ជីទាំងអស់។
- ការធានាទិន្នផលភាគលាភនេះ គឺសម្រាប់វិនិយោគិនគ្រប់រូបដែលទិញមូលបត្រកម្មសិទ្ធិក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈនេះ។

## ២. សង្ខេបអំពីមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់

- ថ្លៃលក់ក្នុងមួយឯកតាភាគហ៊ុន៖ ២.៣៨០ រៀល (០,៥៨៤ ដុល្លារអាមេរិក) *
- ថ្នាក់មូលបត្រកម្មសិទ្ធិ៖ មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"
- ប្រភេទមូលបត្រកម្មសិទ្ធិ៖ ភាគហ៊ុនធម្មតា
- ចំនួនសរុបនៃមូលបត្រកម្មសិទ្ធិសម្រាប់ការធ្វើបរិវិសកម្ម (រហូតដល់ ៣៥%)៖ ៥.០០០.០០០ ទៅ ៦.៤៦១.៥៣៨ ភាគហ៊ុន
- ទំហំទឹកប្រាក់សរុបដែលបោះផ្សាយ ៖ ១១.៩០០.០០០ រៀល (៣,០ លានដុល្លារ អាមេរិក) ទៅ ១៥.៣៧៨.៤៦០.៤៤៤ រៀល (៣,៨៤៥ លានដុល្លារអាមេរិក)
- ទំហំវិនិយោគអប្បបរមា៖ ១០០ ភាគហ៊ុន ២៣៨.០០០ រៀល (~ ៥៨,៤៣៣ ដុល្លារអាមេរិក) *

* អត្រាប្តូរប្រាក់ផ្លូវការនៃធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២១ (៥ ថ្ងៃ មុនថ្ងៃចាប់ផ្តើមបរិវិសកម្ម ៖ ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៧៣ រៀល)

## ៣. ការធ្វើបរិវិសកម្ម

### ក. ការបែងចែកភាគហ៊ុន៖

| ល.រ | វិនិយោគិន | ទំហំបែងចែក | ភាគរយបែងចែក (%) |
|---|---|---|---|
| ១ | វិនិយោគិនជាបុគ្គលិក និយោជិត (ESOP) | ៥០០.០០០ ទៅ ៦៤៦.១៥៤ ភាគហ៊ុន | ១០% |
| ២ | វិនិយោគិនសក្តានុពល | ៣.៤០០.០០០ ភាគហ៊ុន | ៥២,៦២% ~ ៦៨,០០% |
| ៣ | វិនិយោគិនដទៃក្នុងដំណាក់កាលធ្វើបរិវិសកម្ម | ១.១០០.០០០ ទៅ ២.៤១៥.៣៨៤ ភាគហ៊ុន | ២២,០០% ទៅ ៣៧,៣៨% |
| | សរុប | ៥.០០០.០០០ ទៅ ៦.៤៦១.៥៣៨ ភាគហ៊ុន | ១០០,០០% |

### ខ.កាលបរិច្ឆេទ និងទីកន្លែងនៃការធ្វើបរិវិសកម្ម

- កាលបរិច្ឆេទ៖ ថ្ងៃទី២៦ ខែកក្កដា ដល់ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ (វេលាម៉ោង ៨ព្រឹក ដល់ ៥ល្ងាច ពីថ្ងៃធ្វើច័ន្ទ ដល់ថ្ងៃសុក្រ)
- ទីកន្លែងធ្វើបរិវិសកម្ម៖

| ឈ្មោះក្រុមហ៊ុន | អាស័យដ្ឋាន |
|---|---|
| អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី | ជាន់ទី ១៣A អាគារព្រីនស៍ភ្នំពេញថោវើ លេខ ៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ៖ (៨៥៥) ២៣ ៩៩៩ ៥៩៥<br>គេហទំព័រ៖ www.sbiroyal.com |
| អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | អគារការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី (ជាន់ទី៥) អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ៖ ០២៣ ៩៩៩ ៩៦៦ / ៩៩៩ ៩៧៧/ (៨៥៥) ១៥ ៩០០ ២៣៩<br>គេហទំព័រ៖ www.acledasecurities.com.kh |
| កាណា ស៊ីឃ្យូរីធី អិលធីឌី | អាគារលេខ ៣១៥ វិមានកាណាឌីយ៉ា ជាន់ទី១៥ ផ្លូវអង្គឌួង រាជធានីភ្នំពេញ<br>ទូរសព្ទ៖ (៨៥៥)២៣ ៩៩៩ ៨៨៧<br>គេហទំព័រ៖ www.canasecurities.com.kh |
| កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី | #៦៣ ផ្លូវក្រមួនស (១១៤) អគារធនាគារកម្ពុជាសាធារណៈ ជាន់ទី៦ សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរសព្ទ៖ (៨៥៥) ៧០ ៦០៦ ២៩៣ |
| យាន់តាស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី | អគារ Emerald ជាន់ទី៤ លេខ៦៤ (កែងផ្លូវ ១៧៨) សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ៖ (៨៥៥) ២៣-៨៦០ ៨០០/៩២-៧៧៧ ៣០៩<br>គេហទំព័រ៖ www.yuantacambodia.com |
| អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក | ដីឡូត៍លេខ ២១ ជាន់ M, កាច់ជ្រុងផ្លូវលេខ ១១០ & ៩៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ៖ (៨៥៥) ២៣ ៩៦៩ ១៦១<br>គេហទំព័រ៖ www.rhbgroup.com.kh |

### គ. ដំណើរការ និងនីតិវិធី នៃការធ្វើបរិវិសកម្ម

- វិនិយោគិនត្រូវមានគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រណាមួយដែលទទួលបានអាជ្ញាបណ្ណ ពី ន.ម.ក.។
- វិនិយោគិនត្រូវបំពេញពាក្យស្នើសុំចូលរួមបរិវិសកម្ម។
- វិនិយោគិនដែលមានបំណងធ្វើបរិវិសកម្មត្រូវដាក់តម្កល់ប្រាក់ចំនួន ១០០% នៃតម្លៃសរុបនៃមូលបត្រ (លើកលែងវិនិយោគិនជាបុគ្គលិក និងនិយោជិត "ESOP") ទៅក្នុងគណនីបរិវិសកម្មរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ដូចខាងក្រោម៖
  - ឈ្មោះគណនី ៖ ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក - គណនីបរិវិសកម្ម
  - លេខគណនី ៖ 00010407665445 (ប្រាក់រៀល), 00010407665434 (ប្រាក់ដុល្លារអាមេរិក)
  - ឈ្មោះធនាគារ៖ ធនាគារ អេស៊ីលីដា ភីអិលស៊ី
  - លេខកូដស្វីហសម្រាប់គណនីក្រៅប្រទេស (Swift Code) ៖ ACLBKHPP

## ៤. ការប្រកាសលទ្ធផលនៃការធ្វើបរិវិសកម្ម

ក្រុមហ៊ុន ឌី ប៊ី ឌី ដោយមានជំនួយពី ក្រុមហ៊ុន អេសប៊ីអាយ នឹងធ្វើការជូនដំណឹងអំពីលទ្ធផលនៃការធ្វើបរិវិសកម្មដល់វិនិយោគិនបន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ និងទទួលបានការអនុញ្ញាតពី ន.ម.ក។

សម្រាប់ព័ត៌មានពាក់ព័ន្ធនឹងដំណើរការបរិវិសកម្ម សូមទាក់ទង៖

| ឈ្មោះក្រុមហ៊ុន | បុគ្គលទំនាក់ទំនង | អ៊ីមែល | ទូរសព្ទ |
|---|---|---|---|
| ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី | លោក លាង តារា | dleang@sbiroyal.com | (+៨៥៥) ៧៧ ៣៣៣ ៦៣១ |
| | កញ្ញា ប៉ាន់ រ័ត្នគន្ធា | rpann@sbiroyal.com | (+៨៥៥) ៧៨ ៧៧៧ ០៦៤ |

## ៥. ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម អាចទាញយកបានតាមរយៈ៖

| ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម | |
|---|---|
| ឯកសារអេឡិចត្រូនិច៖<br>www.dbdengineering.com<br>www.sbiroyal.com | ឯកសារបោះពុម្ព៖ ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី ជាន់ទី ១៣A អាគារព្រីនស៍ភ្នំពេញថោវើ លេខ ៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ៖ (៨៥៥) ២៣ ៩៩៩ ៥៩៥ |